ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ១១៧,០៣៩៣ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូន យោធិនសមាហរណកម្ម ព្រមទាំងគ្រួសារនៃកងពលតូចលេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន ៤៣ គ្រួសារ និងមួយចំណែក រក្សាទុកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បកចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៣៣/១៧ ល.ស ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៧ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- បានឃើញលិខិតលេខ ១៧៩៧ ដនស/អសដក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញលិខិតលេខ ៧២១៧ កសក ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ **១១៧,០៣៩៣ ហិកតា** ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនយោធិនសមាហរណកម្មព្រមទាំងគ្រួសារ នៃកងពលតូចលេខ ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹកចំនួន **៤៣ គ្រួសារ** ទំហំ **១១៣,៧៩៧១ ហិកតា** និងផ្ទៃដីទំហំ **៣,២៤២២ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនយោធិនសមាហរណកម្មព្រមទាំងគ្រួសារ នៃកងពលតូចលេខ៣១ បញ្ជាការដ្ឋានកងទ័ពជើងទឹក នៅភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត ។

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..........១៧៥ អនក្រ.បក..........ចុះថ្ងៃទី..២០.....ខែ...តុលា......ឆ្នាំ ២០១៧ ស្តីពីការកាត់ដីទំហំ ១១៧,០៣៩៣ ហិកតា នៅភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៣ គ្រួសារ កាន់កាប់ដាំដុះជាក់ស្តែង និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




| ចំណុច | Y | X |
|---|---|---|
| 1 | 1221038 | 415517 |
| 2 | 1221147 | 415323 |
| 3 | 1221202 | 415200 |
| 4 | 1221234 | 415020 |
| 5 | 1221298 | 414602 |
| 6 | 1221279 | 414505 |
| 7 | 1221163 | 414295 |
| 8 | 1221081 | 414208 |
| 9 | 1221668 | 414012 |
| 10 | 1221648 | 413954 |
| 11 | 1221612 | 413871 |
| 12 | 1221844 | 413846 |
| 13 | 1222040 | 413824 |
| 14 | 1222107 | 413900 |
| 15 | 1222147 | 414515 |
| 16 | 1222003 | 414540 |
| 17 | 1221959 | 414700 |
| 18 | 1221971 | 414792 |
| 19 | 1221975 | 414881 |
| 20 | 1221971 | 414941 |
| 21 | 1221946 | 415038 |
| 22 | 1221914 | 415137 |
| 23 | 1221897 | 415192 |
| 24 | 1221850 | 415335 |
| 25 | 1221834 | 415375 |
| 26 | 1221665 | 415440 |
| 27 | 1221542 | 415412 |
| 28 | 1221262 | 415471 |




## សញ្ញាសម្គាល់

- ភូមិ
- ឃុំ
- ដីភ្នំ
- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ១១៧,០៣៩៣ ហិកតា
- ចំនុចគោល
- ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ១១៣,៧៩៧១ ហិកតា
- រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ១,២៤២២ ហិកតា
- ស្ទឹង
- ផ្លូវ

**ទិន្នន័យគម្របព្រៃឈើ២០០២**

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ដីគ្មានគម្របព្រៃ

Coordinate System Projection UTM
Zone 48N Map Datum:WGS84

N

មាត្រដ្ឋាន 1:12,000

0 165 330 660 990 1,320 Meters

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...............១៧៥អនក្រ.បក.........ចុះថ្ងៃទី...២៨....ខែ...តុលា......ឆ្នាំ ២០១៧ស្ដីពីការកាត់ដីទំហំ ១១៧,០៣៩៣ ហិកតា នៅភូមិជ័យសេនា ឃុំតាកែន ស្រុកឈូក ខេត្តកំពត ចេញពីតម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៣ គ្រួសារ កាន់កាប់ដាំដុះជាក់ស្ដែង និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ**




| ចំណុច | Y | X |
|---|---|---|
| 1 | 1221038 | 415517 |
| 2 | 1221147 | 415323 |
| 3 | 1221202 | 415200 |
| 4 | 1221234 | 415020 |
| 5 | 1221298 | 414602 |
| 6 | 1221279 | 414505 |
| 7 | 1221163 | 414295 |
| 8 | 1221081 | 414208 |
| 9 | 1221668 | 414012 |
| 10 | 1221648 | 413954 |
| 11 | 1221612 | 413871 |
| 12 | 1221844 | 413846 |
| 13 | 1222040 | 413824 |
| 14 | 1222107 | 413900 |
| 15 | 1222147 | 414515 |
| 16 | 1222003 | 414540 |
| 17 | 1221959 | 414700 |
| 18 | 1221971 | 414792 |
| 19 | 1221975 | 414881 |
| 20 | 1221971 | 414941 |
| 21 | 1221946 | 415038 |
| 22 | 1221914 | 415137 |
| 23 | 1221897 | 415192 |
| 24 | 1221850 | 415335 |
| 25 | 1221834 | 415375 |
| 26 | 1221665 | 415440 |
| 27 | 1221542 | 415412 |
| 28 | 1221262 | 415471 |

Coordinate System Projection UTM Zone 48N Map Datum:WGS84

វាស់វែង ដោយប្រើឧបករណ៍ GPS MAP 62s

កំពត, ថ្ងៃទី..០៥........ខែ...មករា..ឆ្នាំ២០១៧

អ្នកវាស់វែង

លេខ...២៨៥...៦...ឃឹត ចាន់

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពត, ថ្ងៃទី...០៥...ខែ..មករា...ឆ្នាំ២០១៧

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

យឹម-វុទ្ធី

លេខ.........

បានឃើញ និងឯកភាព

កំពត, ថ្ងៃទី...១២...ខែ..មករា...ឆ្នាំ២០១៧

អភិបាលខេត្ត និងជា

ប្រធានគណៈកម្មការរដ្ឋបាលគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

ចាន់ ខេស្ដា